# សហគមន៍ខ្មែរកម្ពុជាក្រោម - ទ្វីបអាមេរិកខាងជើង

**THE KHMER KAMPUCHEA KROM COMMUNITY-NORTH AMERICA**
**LA COMMUNAUTÉ DU KHMER KAMPUCHEA KROM- L'AMÉRIQUE DU NORD**

## សុន្ទរកថា

**លោក គិម ប.ម. សកល**

**នាយកប្រតិបត្តិសហគមន៍ខ្មែរកម្ពុជាក្រោម ប្រចាំទ្វីបអាមេរិកខាងជើង**

**ឱកាសបុណ្យសពលោកស្រី កៀង ធី សយ ភរិយាលោក ថាច់ វ៉ែន**

**ថ្ងៃសៅរ៍ ០២រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ឯកស័ក ព.ស.២៥៥៣ ត្រូវនឹងថ្ងៃទី០៨ ខែសីហា គ.ស.២០០៩**

**កោះឈៅណៃម៉ូ ខេត្តប្រ៊ីតធីសកូឡុំប៊ីយ៉ា ប្រទេសកាណាដា**

**អានដោយលោក សឺន យុន ធឿង ប្រធានគណៈប្រតិភូ និងជាអគ្គលេខាធិការ ស.ខ.ក.**

-សូមនមស្សការប្រជុំបីនៃព្រះត្រៃរតន៍

-សូមគោរពព្រះវិញ្ញាណក្ខ័ន្ធព្រះវីរសមណ: និងវិញ្ញាណក្ខ័ន្ធវីរបុរស វីរនារី និងអតីតយុទ្ធជនស្នេហាជាតិខ្មែរទាំងអស់

-សូមថ្វាយបង្គំព្រះថេរានុត្ថេរ: គ្រប់ព្រះអង្គជាទីគោរពសក្ការ:ដ៏ខ្ពង់ខ្ពស់

-សូមគោរពវិញ្ញាណក្ខ័ន្ធសពលោកស្រី កៀង ធី សយ

-សូមគោរពលោក ថាច់ វ៉ែន និងគ្រួសារសព ជាទីមេត្រី

-សូមគោរពលោក និង លោកស្រី តំណាងបណ្តាស្ថាប័នជាតិនានា ព្រមទាំងលោក លោកស្រី អ្នកនាងកញ្ញា ពុទ្ធបរិស័ទ និង បងប្អូនជនរួមជាតិ ជាទីស្នេហា

សហគមន៍ខ្មែរកម្ពុជាក្រោម ថ្នាក់ដឹកនាំ គណៈប្រតិភូ (លោក ទេព សួន លោក ថាច់ លែម និង ............) សហការី សមាជិក សមាជិកា និងរូបខ្ញុំព្រះករុណា ខ្ញុំបាទផ្ទាល់ សូមចូលរួមចំណែកកាន់ទុក្ខដ៏ក្រៀមក្រំចំពោះសពលោកស្រី កៀង ធី សយ ហៅ កៀង ធី ជា ភរិយាលោក ថាច់ វ៉ែន និងជាអ្នកម្តាយជាទីគោរពស្រឡាញ់របស់កូនប្រុសស្រីលោកទាំងពីរ ។

មរណភាពរបស់លោកស្រី កៀង ធី សយ ជាការបាត់បង់ធំធេងណាស់ មិនតែសម្រាប់ក្រុមគ្រួសាររបស់លោក ថាច់ វ៉ែន នោះទេ គឺសម្រាប់សង្គមខ្មែរទាំងមូល។

លោកស្រី កៀង ធី សយ ជាសកម្មជនម្នាក់បានតស៊ូពុះពារក្នុងឆាកជីវិតជិត ៥៧ឆ្នាំកន្លងមកនេះដ៏លំបាកលំបិន តាំងពីនៅលើទឹកដីកំណើតកម្ពុជាក្រោម ជាទីស្នេហារបស់យើងដ៏ច្រើនរូប ទាំងនៅប្រទេសកម្ពុជា ទាំងនៅជំរុំជនភៀសខ្លួនជំនាន់ប្រទេសយួនឈ្លានពាននិងកាន់កាប់ទឹកដីកម្ពុជា ហើយនិង នៅចុងក្រោយបំផុតនៃជីវិតលោកស្រី លោកស្រីបានចូលរួមយ៉ាងសកម្មជាមួយស្វាមីលោកស្រីតស៊ូមតិ ដើម្បីសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋខ្មែរក្រោម ក្នុងបុព្វហេតុជាតិខេមរា ព្រះពុទ្ធសាសនា ភាសាសាស្ត្រ អក្សរសាស្ត្រ អរិយធម៌ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ និងបរិស្ថាន ពិសេសកម្ពុជាក្រោម ។

លោកស្រី កៀង ធី សយ ជាស្ត្រី ប្រជាពលរដ្ឋ និងជាពុទ្ធសាសនិកជនដ៏ល្អគ្មានពីរ ។

ថ្នាក់ដឹកនាំ គណៈប្រតិភូ សហការី សមាជិកមួយចំនួនច្រើន បងប្អូនជនរួមជាតិ និងខ្ញុំព្រះករុណា ខ្ញុំបាទផ្ទាល់ មានឱកាសជួបនិងស្គាល់លោកស្រី កៀង ធី សយ កាលនៅកម្ពុជាក្រោម សហរដ្ឋអាមេរិក និងនៅប្រទេសកាណាដា ។ នៅលើកចុងក្រោយនោះ គឺនៅក្នុងទិវាកាន់ទុក្ខជាតិខ្មែរគម្រប់ខួប ៥៩ឆ្នាំ ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ ១៩៤៩ ថ្ងៃអាណានិគមនិយមបារាំងកាត់ទឹកដីខ្មែរ កម្ពុជាក្រោម ឱ្យចក្រពត្តិយួនត្រួតត្រារហូតសព្វថ្ងៃ និងពិធីបុណ្យរាប់បាត្រព្រះសង្ឃ ១៩៤៩អង្គ ដើម្បីឧទ្ទិសកុសលថ្វាយ ប្រគេន និងជូន ព្រះវិញ្ញាណក្ខ័ន្ធព្រះវីរសមណៈ និងវិញ្ញាណក្ខ័ន្ធវីរបុរស វីរនារី និងអតីតយុទ្ធជនស្នេហាជាតិខ្មែរ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នាឆ្នាំ២០០៨ នៅក្នុងឱកាសពិធីបុណ្យសពវិសាមញ្ញព្រះមហាថេរ៍ ព្រះភិក្ខុ សុវណ្ណប្បញ្ញោ ថាច់ សួន នៃវត្តសុរិន្ទរាជព្រឹក្ស ស្លាប៉ាង កម្ពុជាក្រោម នៅសហរដ្ឋអាមេរិក នាឆ្នាំ២០០៨កន្លងមក ហើយនិង នៅក្នុងឱកាសសន្និបាតប្រចាំឆ្នាំ២០០៦របស់សហគមន៍ខ្មែរកម្ពុជាក្រោមនៃទ្វីបអាមេរិកខាងជើង ក្រោមអធិបតីភាពអតីតសមាជិកព្រឹទ្ធសភាកម្ពុជា លោក ថាច់ សេដ្ឋា និងជានាយកប្រតិបត្តិសហគមន៍ខ្មែរកម្ពុជាក្រោម។

**បពិត្រព្រះថេរានុត្ថេរៈ**
**លោក លោកស្រី និងបងប្អូនជនរួមជាតិ ជាទីស្នេហា**

ថ្នាក់ដឹកនាំ គណៈប្រតិភូ សហការី សមាជិក បងប្អូនជនរួមជាតិ និងខ្ញុំព្រះករុណា ខ្ញុំបាទបានកត់ត្រានៅក្នុងបេះដូងរបស់យើងខ្ញុំព្រះករុណា យើងខ្ញុំរួចទៅហើយនូវមនសិការជាតិ សាសនា និងអំពើបម្រើជាតិមាតុភូមិទាំងប៉ុន្មានរបស់លោកស្រី កៀង ធី សយ ។ វត្ថុទាំងអស់នោះ ពុំអាចកាត់ថ្លៃបានឡើយ ។ លោកស្រីបានបន្សល់ទុកនូវគំរូល្អសម្រាប់កុលបុត្រ កុលធីតាខ្មែរជំនាន់ក្រោយឱ្យចេះស្រឡាញ់ជាតិកម្ពុជា និងសាសនា ដូចលោកស្រី ដូនតា និងបុព្វបុរសរបស់យើងដែរ។

នៅគ្រាអវសាន្តនៃការចូលរួមរំលែកមរណទុក្ខនេះ ក្នុងនាមថ្នាក់ដឹកនាំ គណៈប្រតិភូ សហការី សមាជិក និងខ្ញុំព្រះករុណា ខ្ញុំបាទ សូមលើកដៃប្រណម្យសូងដល់គុណបុណ្យព្រះរតនត្រ័យ ទេវតា ព្រះឥន្ទព្រហ្ម និងវត្ថុស័ក្តិសិទ្ធនៅក្នុងលោក តាមបីបាច់ថែរក្សាព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ លោក ថាច់ វ៉ែន និងគ្រួសារ លោក លោកស្រី អ្នកនាងកញ្ញា ពុទ្ធបរិស័ទ និងបងប្អូនជនរួមជាតិ ជួបប្រទះតែពុទ្ធពរទាំងប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។

ដោយឥដ្ឋមនុញ្ញផល ដែលលោកស្រី កៀង ធី សយ បានកសាងនៅក្នុងជាតិនេះ សូមលោកស្រីអញ្ជើញទៅសោយសុខក្នុងសុគតិភពកុំបីខាន។

សហគមន៍ខ្មែរកម្ពុជាក្រោម សូមថ្លែងអំណរព្រះគុណ និងអំណរគុណ យ៉ាងជ្រាលជ្រៅចំពោះព្រះថេរានុត្ថេរៈ សព លោកស្រី កៀង ធី សយ លោក ថាច់ វ៉ែន និងគ្រួសារ លោកស្រី ថាច់ ធី ស និងគ្រួសារ លោក ថាច់ ង៉ាង និងគ្រួសារ លោក លោកស្រី អ្នកនាងកញ្ញា និងបងប្អូនជនរួមជាតិ នៅប្រទេសកាណាដា សហរដ្ឋអាមេរិក និងនៅក្រៅប្រទេសដទៃទៀត ដែលមានមនសិការជាតិខ្ពស់ បាននិងបន្តគាំទ្រនិងឧបត្ថម្ភសហគមន៍យើងខ្ញុំព្រះករុណា យើងខ្ញុំ តាមកម្លាំងកាយ កម្លាំងចិត្ត ស្មារតី និងថវិកា ដើម្បីផ្តល់លទ្ធភាពឱ្យសហគមន៍ខ្មែរកម្ពុជាក្រោម ការពារផលប្រយោជន៍សិទ្ធិសេរីភាពរបស់ព្រះសង្ឃ និង បងប្អូនរួមឈាមខ្មែរកម្ពុជាក្រោម ជាទីស្នេហានៃយើង។

សូមអរព្រះគុណ និងសូមអរគុណ។



-----------------------------------------------------------------------------------------------------------
Website: www.khmerkromngo.org
Mailing address in the United States & Canada: P.O. Box 1836, Lowell, MA 01853 U.S.A.
E-mail: KKCpressoffice@yahoo.com